

Jeudi 2 novembre 13h50, l'arrivée à Pochentong.
Premier sourire au pays khmer.

# MADAME JACQUELINE KENNEDY AU CAMBODGE
## *(2—8 NOVEMBRE)*

Les événements du mois

**4**



Les premières personnalités du royaume et le corps diplomatique lui sont présentés.
Ci-dessus, madame Kennedy et l'ambassadeur de l'Union soviétique M. Anatoly Ratanov.




Samdech lui ayant, le premier, souhaité la bienvenue et une gerbe de précieuses orchidées lui ayant été offerte par la jeune princesse Norodom Arunrasmey, fille cadette du prince, madame Kennedy accompagnée de celui-ci se dirige vers le hall d'accueil de l'aéroport. Le parasol royal est tenu au-dessus d'elle et de Samdech. Les lanciers et les porte-rotins de l'ancienne garde des souverains l'escortent. Deux cents jeunes filles en sampot de soie écarlate jettent pétales de rose et fleurs de jasmin sur le tapis de pourpre déroulé sous ses pas.

# LA VISITE DE MADAME JACQUELINE KENNEDY AU CAMBODGE



# ទស្សនកិច្ចលោកជំទាវ កេណ្ណឌី នៅ ប្រទេសកម្ពុជា



សម្តេចសហជីវិនទ្រង់បានជូនលោកជំទាវមកដល់ព្រះមហាប្រាសាទខេមរិន្ទ

កាលពីថ្ងៃព្រហស្បតិ៍ ទី ២ វិច្ឆិកា ១៩៦៧ ពេលម៉ោង ១៣ និង ៤០ នាទី លោកជំទាវ ហ្សាក្លីន កេណ្ណឺឌី ដែលជាភរិយានៃលោក ហ្ស៊ុនកេណ្ណឺឌី អតីតប្រធានាធិបតីនៃសហរដ្ឋអាមេរិក បានអញ្ជើញតាមយន្តហោះពិសេស មកដល់ចំណតយន្តហោះពោធិចិនតុង ដើម្បីធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ក្នុងក្របខ័ណ្ឌជាអ្នកទេសចរណ៍ ។

នៅពេលដែលលោកជំទាវ ហ្សាក្លីន កេណ្ណឺឌី អញ្ជើញមកដល់នោះ សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ដោយមានព្រះរាជវង្សានុវង្ស-ឥស្សរជនជាន់ខ្ពស់, លោកជំទាវ-លោកស្រី និង សមាជិកគណៈរដ្ឋាភិបាល, សមាជិកសភាទាំងពីរ ព្រមទាំងមន្ត្រីរាជការគ្រប់ផ្នែក បានស្តេចយាង និងអញ្ជើញទៅទទួលនៅឯចំណតយន្តហោះពោធិចិនតុង ។

ក្រៅពីនេះមានលោកសាស្ត្រាចារ្យ-លោកគ្រូ-អ្នកគ្រូ-ក្រុមយុវជនយុវតី-សិស្សសាលា និងប្រជាពលរដ្ឋជាច្រើនម៉ឺននាក់ ដែលបានតុបតែងខ្លួនយ៉ាងស្អាតបាត បានទៅទទួលលោកជំទាវនៅចំណតយន្តហោះ និងនៅតាមដងផ្លូវចាប់តាំងពីចំណតយន្តហោះពោធិចិនតុង រហូតមកដល់ព្រះបរមរាជវាំង ។

នៅពេលចុះពីយន្តហោះ លោកជំទាវ ហ្សាក្លីន កេណ្ណឺឌី បានទទួលផ្កាអរគីដេមួយបាច់ធំ ពីព្រះអង្គម្ចាស់ក្សត្រី អរុណរស្មី និងបានទទួលការអបអរសាទរជាទីបំផុតពីសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ហើយនិងឥស្សរជនខ្មែរ នៅមាត់ជណ្តើរនៃយន្តហោះ ។

តមក សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានអញ្ជើញលោកជំទាវ ហ្សាក្លីន កេណ្ណឺឌី ធ្វើដំណើរកាន់វេទិកាកិត្តិយស ដោយបានអញ្ជើញតាមកម្រាល មានពណ៌ក្រហមស្រស់ ដែលមាននារីខ្មែរជាច្រើននាក់ ប្រកបដោយរូបឆោមយ៉ាងប្រិមប្រិយ៍ស្រស់ បានបាចផ្កាម្លិះរោយរាយតាមដំណើរអញ្ជើញនៃលោកជំទាវរហូតដល់វេទិកាកិត្តិយស ។

ក្រោយដែលបានសម្រាកកាយនៅក្នុងវេទិកាកិត្តិយសបន្តិចមក សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានស្តេចអញ្ជើញលោកជំទាវហ្សាក្លីន កេណ្ណឺឌី ឡើងរថយន្តជាមួយព្រះអង្គ ដោយមានក្បួនដង្ហែជាផ្លូវការអមដំណើរផង ឆ្ពោះមកកាន់កម្ពុជាធានីភ្នំពេញ ហើយបានដល់ព្រះបរមរាជវាំង នៅម៉ោង ១៤ និង ៣០ នាទី ។

នៅក្នុងព្រះបរមរាជវាំង លោកជំទាវហ្សាក្លីនកេណ្ណឺឌី បានទទួលសេចក្តីអបអរសាទរ អំពីក្រុមសិស្សនារីនៃវិទ្យាល័យជាច្រើនរយនាក់ទៀត ហើយបន្ទាប់មកលោកជំទាវក៏បានអញ្ជើញចូលទៅសម្រាកកាយនៅក្នុងព្រះមហាប្រាសាទខេមរិន្ទ ដោយសុវត្ថិភាព ។

ទំព័រ ៨

# ដំណើរទស្សនកិច្ចនៃ
# លោកជំទាវហ្សាក់គីលីន-កេណ្ណឌី
# នៅប្រទេសកម្ពុជា



▲ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានថ្វាយហត្ថសម្ពះព្យចំពោះសម្តេចឪ

## ពិធីលៀងសាយភោជន៍ និងការសម្តែងសិល្បៈ



▲ លោកជំទាវ ហ្សាក់គី-លីន កេណ្ណឌី បានទទួលបដិសណ្ឋារកិច្ចផ្ទាល់ និងការសន្ទនាដោយរីករាយអំពីសម្តេចឪ

នៅរាត្រីនៃថ្ងៃទី ២ វិច្ឆិកា ១៩៦៧ លោកជំទាវហ្សាក់គីលីន កេណ្ណឌី និងមិត្តទាំងឡាយរបស់លោកជំទាវ បានអញ្ជើញទៅទទួលសាយភោជន៍នៅក្នុងវិមានរដ្ឋាព្រះជំណាក់ចំការមន ដែលសម្តេចសហជីវិនព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យរៀបចំប្រទានជាកិត្តិយសចំពោះលោកជំទាវ ។

ភ្ញៀវកាលនោះ មានអ្នកស្រុកផងខ្មែរ-បរទេស ព្រមទាំងលោកជំទាវជាច្រើនរូបបានអញ្ជើញទៅរួមផង ។



► សម្តេចឪ និងលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានលើកកែវឡើងប្រសិទ្ធិចំពោះសុខភាពផ្ទាល់ និងសុខភាពនៃប្រជាជាតិទាំងពីរ

នៅក្នុងពិធីដ៏មហោឡារិកនេះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋទ្រង់បានថ្លែងព្រះរាជសុន្ទរកថាមួយ ។ ហើយតមកលោកជំទាវហ្សាក្លីលីន កេណ្ណឌី ដោយមានសេចក្ដីរំភើបខ្លាំងពេកក៏បានថ្លែងតបវិញយ៉ាងខ្លីថា៖ «សូមអរព្រះគុណសម្ដេច» រួចលោកជំទាវហ្សាក្លីលីនកេណ្ណឌី ក៏ស្រក់ទឹកភ្នែក ជាការបញ្ជាក់ឲ្យឃើញនូវសេចក្ដីរំជួលចិត្តនិងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅរបស់លោកជំទាវថ្វាយចំពោះសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ។

លុះចប់ពិធីលៀងសាយភោជន៍នេះហើយ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ក៏បានអញ្ជើញលោកជំទាវហ្សាក្លីលីនកេណ្ណឌី ទៅកាន់សាលបន្ទប់មុខ ដើម្បីទស្សនាល្ខោនព្រះរាជទ្រព្យដែលមានព្រះអង្គម្ចាស់ក្សត្រីបុប្ផាទេវីទ្រង់ជាតួឯក និងទស្សនាក្រុមចម្រៀងជាពួក, ក្រុមតន្ត្រី ព្រមទាំងក្រុមសិល្បៈតាមទំនៀមទម្លាប់របស់សាលាភូមិន្ទសាកលវិទ្យាល័យសិល្បៈជាដើម ។ ការសម្ដែងសិល្បៈក្នុងរាត្រីនេះ បានធ្វើឲ្យភ្ញៀវខ្មែរ-បរទេសជាង ៧០០ នាក់ មានការចាប់អារម្មណ៍និងសប្បាយរីករាយយ៉ាងក្រៃលែង ។

១



សម្ដេចឪ ទ្រង់បានបង្ហាញវត្ថុអនុស្សាវរីយ៍ដ៏មានតម្លៃចំពោះលោកជំទាវ ហ្សាក់កលីន កេណ្ណឌី



ល្ខោនព្រះរាជទ្រព្យ បានសំដែងតួយក្ស និងនាងកំពុងបញ្ចេញក្បាច់រាំតាមបែបបុរាណខ្មែរ ▲



លោកជំទាវ ហ្សាក់កលីន កេណ្ណឌី និងសម្ដេចឪ កំពុងទស្សនារបាំព្រះរាជទ្រព្យ ▲

ក្រុមល្ខោនព្រះរាជទ្រព្យ បានសំដែងនូវក្បាច់រាំជាគូៗនៃស្ត្រីនិងបុរសតាមបែបបុរាណ ▶



# ការទស្សនាប្រាសាទអង្គរ សៀមរាប



ទេសភាពប្រាសាទអង្គរវត្តក្នុងពេលរាត្រី







នៅព្រឹកថ្ងៃទី៣វិច្ឆិកា ១៩៦៧ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី ដែលមានបំណងជាយូរឆ្នាំមកហើយក្នុងការទស្សនាប្រាសាទអង្គរនោះ ក៏បានអញ្ជើញតាមយន្តហោះទៅកាន់ខេត្តសៀមរាបដោយមានផុស្សដែនខ្មែរជាច្រើនរូបជូនដំណើរផង ។ ហើយបានស្នាក់នៅខេត្តសៀមរាបចំនួន ៣ ថ្ងៃ ។

នៅពេលអញ្ជើញទៅដល់ខេត្តសៀមរាប លោកជំទាវ ហ្សាក់គី-លីន កេណ្ណឌី បានទទួលការអបអរពីសហជីវិនអភិបាលខេត្ត, មន្ត្រីរាជការក្នុងខេត្ត, ក្រុមយុវជន-យុវតីសិស្សសាលានិងពីប្រជាពលរដ្ឋជាច្រើនម៉ឺននាក់ ដែលបានមករង់ចាំទទួលនៅចំណតយន្តហោះនិងតាមផ្លូវហូតមកដល់ទីក្រុងសៀមរាប ។

នៅថ្ងៃទី ៣ វិច្ឆិកា ១៩៦៧ នេះ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទស្សនាប្រាសាទបាយ័ន ស្រះស្រង់ និងប្រាសាទអង្គរវត្ត ។ នៅពេលបន្ទាប់គ្នានេះ លោកជំទាវ បានទស្សនានូវរបាំបុរាណខ្មែរ គឺ



លោកអភិរក្សប្រាសាទអង្គរ កំពុងនិយាយពន្យល់រូបចម្លាក់នៅថែវប្រាសាទអង្គរវត្ត ចំពោះលោកជំទាវ ហ្សាក់-គីលីន កេណ្ណឌី

# ដំណើរទស្សនាការនៃ លោកជំទាវហ្សាក់គីលីន-កេណ្ណឌី នៅប្រទេសកម្ពុជា



ក្រុមសិល្បករនៃភូមិន្ទសាកលវិទ្យាល័យសិល្បៈ បានសំដែងរបាំទន្សោងធ្វូន
លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី



លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានអង្គុយសម្រាកកាយ នៅទីលានស្រះស្រង់

របាំត្រុដិ ទន្សោងនិងឆៃយ៉ាំ ។

នៅព្រឹកថ្ងៃ៤ វិច្ឆិកា ១៩៦៧ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានអញ្ជើញទស្សនាប្រាសាទបន្ទាយស្រី និងទស្សនារបាំក្ងោក ដែលសំដែងឡើងដោយសិល្បករនៃមហាវិទ្យាល័យសិល្បៈ ។ លុះដល់ត្រឡប់មកកាន់ខេត្តសៀមរាបវិញ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទស្សនាមន្ទីរទេសចរណ៍ខេត្ត និងទស្សនាផ្សារសៀមរាប ។ នៅពេលទស្សនាផ្សារនេះ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទិញគ្រឿងស្បែក ចម្លាក់ និងគ្រឿងតម្បាញជាច្រើន ដើម្បីយកទៅទុកជាអនុស្សាវរីយ៍ ។

នៅពេលសៀល លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទស្សនាប្រាសាទអង្គរធំ ធម្មនន្ទ, ចៅសាយទេវតា, តាកែវ និងតាព្រហ្ម។

នៅថ្ងៃទី ៥ វិច្ឆិកា ១៩៦៧ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានអញ្ជើញទស្សនាប្រាសាទបាពួន ព្រះខ័ន នាគព័ន្ធ ភិមានអាកាស និងស្រះស្រី-ស្រះធ្លុប ។

ក្នុងការទស្សនាប្រាសាទបុរាណទាំង ៣ ថ្ងៃនេះ លោកជំទាវ ហ្សាក់គីលីនកេណ្ណឌី និងមិត្តលោកជំទាវ បានចាប់អារម្មណ៍និងលាន់មាត់សើចសរសើរយ៉ាងខ្លាំង ចំពោះស្នាដៃនៃបុព្វបុរសខ្មែរ ដែលបានស្ថាបនាប្រាសាទនិងស្រះស្រង់ ទុកជាអនុស្សាវរីយ៍បង្ហាញពិភពលោកឲ្យឃើញនូវវឌ្ឍនភាព-ចំរើនរុងរឿង-ខ្លាំងពូកែនៃជនជាតិខ្មែរ ។

ក្រោយដែលលោកជំទាវ



## ដំណើរទស្សនកិច្ចនៃ
## លោកជំទាវហ្សាក់គីលីន
## កេណ្ណឌី
## នៅប្រទេសកម្ពុជា

◀ ការទស្សនាប្រាសាទបន្ទាយស្រី ក្រោម ការ ដឹក នាំ និង ការ ពន្យល់ នៃ លោកគ្រោស្លីយេអភិរក្សប្រាសាទអង្គរ







## ការទស្សនាប្រាសាទអង្គរ សៀមរាប

ហ្សាក់គីលីនកេណ្ណឌី បានសំណាក់
នៅខេត្តសៀមរាប និងទស្សនា
ប្រាសាទអង្គរអស់រយៈកាល ៣ ថ្ងៃ
រួចហើយ នៅព្រឹកថ្ងៃទី ៦ វិច្ឆិកា
១៩៦៧ លោកជំទាវក៏បានអញ្ជើញ
តាមយន្តហោះចេញពីខេត្តសៀម-
រាប ឆ្ពោះមកកាន់ទីក្រុងព្រះសីហនុ
ដើម្បីទស្សនាក្នុងទីក្រុង និងចូលរួម
សម្ពោធដាក់ឈ្មោះវិថីថ្មី នៅក្នុង
ទីក្រុងព្រះសីហនុដែលមានឈ្មោះថា:
«វិថី ហ្សូ-ហ្វ កេណ្ណឌី» ។



▲ ការទស្សនារបាំក្អែក សម្ដែងរឿងដោយក្រុមសិល្បករនៃភូមិន្ទសាកលវិទ្យាល័យសិល្បៈ

# ដំណើរទស្សនកិច្ចនៃ
# លោកជំទាវហ្សាក់គីលីន-កេណ្ណឌី
# នៅប្រទេសកម្ពុជា

## ពិធីសម្ពោធដាក់នាមវិថីថ្មី "វិថី ហ្ស-ហ្វ-កេណ្ណឌី"



លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី និង សម្ដេចសហជីវិន បានធ្វើដំណើរតាមវិថីហ្ស. ហ្វ. កេណ្ណឌី



លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានថ្លែងសុន្ទរកថាក្នុងឱកាសសម្ពោធវិថីហ្ស. ហ្វ. កេណ្ណឌី ។



លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី និងសម្ដេច បានសន្ទនាការលើរថយន្ត

កាលពីព្រឹកថ្ងៃ ទី ៦ វិច្ឆិកា ១៩៦៧ សម្ដេចឪ ទ្រង់បានស្ដេចយាងគង់លើព្រះទីនាំងទទួម្ដាតបក្រ ចេញពីកដាទីភ្នំពេញឆ្ពោះទៅកាន់ទីក្រុងព្រះសីហនុ ដើម្បីទ្រង់ជាព្រះអធិបតី ក្នុងពិធីសម្ពោធដាក់នាមវិថី «វិថីហ្ស-ហ្វ កេណ្ណឌី» ។

នៅពេលស្ដេចយាងទៅដល់ចំណតយន្តហោះ នៃក្រុងព្រះសីហនុ ហើយសម្ដេចឪ ទ្រង់បានអញ្ជើញលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី ដែលជាភ្ញៀវដ៏ឧត្ដមរបស់សម្ដេចឪ និងប្រជាពលរដ្ឋខ្មែរនោះ ជិះនៅលើរថយន្តពិសេសរបស់ព្រះអង្គឆ្ពោះទៅកាន់ព្រះពន្លាពិសេស ដែលបានរៀបនាដោយស្លឹកត្រូ ជាតិ និងទង់ជាតិ យ៉ាងល្អវិចិត្រ ដើម្បី



សាស្ត្រាចារ្យ-អ្នកគ្រូ និង សិស្សានុសិស្ស-យុវជន-យុវតី-ប្រជាពលរដ្ឋប្រុស-ស្រី បានសំដែងសេចក្ដីអបអរសាទរទទួលលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី និង សម្ដេចឪនៅក្រុងព្រះសីហនុ

# ដំណើរទស្សនាការ
# នៃលោកជំទាវហ្សាក់គីលីន-កេណ្ណឌី
# នៅប្រទេសកម្ពុជា



លោកជំទាវបានថ្លែងសុន្ទរកថារំលឹកដល់ មិត្តភាពខ្មែរ-អាមេរិកាំង
ក្នុងឱកាសសម្ពោធវុក្ខវិថីហ្ស.ហ្វ កេណ្ណឌី




▲ សម្ដេចឪទ្រង់នាំលោក ជំទាវហ្សាក្គី-លីន កេណ្ណឌី ឆ្ពោះទៅកាន់ផ្ទាំងអក្សរ ចារឹកនាមវុក្ខវិថីនោះ ▼





សម្ដេចឪទ្រង់នាំលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី
ទស្សនាទេសភាពនៃព្រឹក្សាសម្រាប់ក្រុងព្រះសីហនុ

អ្នកជាតិនិយម ថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ១៩៦៧ ទំព័រ ១៦



ក្រុមតន្ត្រីមហោរីព្រះបរមរាជវាំងប្រគំនូវបទដំលែងពីរោះជូនលោកជំទាវ
ហ្សាក្គីលីន កេណ្ណឌី



ក្រុមរបាំប្រជាប្រិយ បានរាំរបាំប្រជាការ ជូនលោកជំទាវ ហ្សាក្លីន កេណ្ណឌី ទស្សនា



ទេសភាពនៃព្រះរាជដំណាក់ នៅក្រុងព្រះសីហនុក្នុងពេលរាត្រី





លោកជំទាវ ហ្សាក្លីន កេណ្ណឌីបានទទួលការជប់លៀង យ៉ាងប្រណីតអំពីសម្តេចឪ

# ពិធីសម្ពោធដាក់នាមរុក្ខវិថីថ្មី រុក្ខវិថី ហ្ស-ហ្វ កេណ្ណឌី

សម្ពោធដាក់នាមរុក្ខវិថីថ្មី ដែលមាននាមថា : «រុក្ខវិថី ហ្ស-ហ្វ កេណ្ណឌី» តាមស្វាមីរបស់លោកជំទាវ ហ្សាក្លីនកេណ្ណឌី ។

ក្នុងឱកាសនោះសម្តេចឪ និងលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទទួលការគោរពថ្វាយបង្គំ និងទទួលការអបអរសាទរពីមន្ត្រីរាជការ យុវជនយុវតី-សិស្សសាលា និងប្រជាពលរដ្ឋជាច្រើនម៉ឺននាក់ ដែលបានមករួមក្នុងពិធីនេះ ។

ក្រោយដែលបានធ្វើពិធីផ្សេងៗ តាមផ្លូវការរួចហើយ សម្តេចឪទ្រង់បានថ្លែងព្រះរាជសុន្ទរកថាមួយ មានអត្ថន័យយ៉ាងពីរោះ - ហើយតមកលោកជំទាវ ហ្សាក្លីនកេណ្ណឌី ក៏បានថ្លែងសុន្ទរកថាតបវិញ ។ នៅគ្រប់ចំណុចនៃព្រះរាជសុន្ទរកថានិងសុន្ទរកថានេះ ប្រជាពលរដ្ឋបានទះដៃសំដែងនូវសេចក្តីពេញចិត្ត យ៉ាងក្រៃលែង ។

លុះចប់ព្រះរាជសុន្ទរកថា និងសុន្ទរកថានេះហើយ សម្តេចឪទ្រង់បានអញ្ជើញលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី ទៅបើកវាំងននសំពត់ ដែលគ្របផ្ទាំងសិលាចារឹក នាមផ្លូវថា : «រុក្ខវិថី ហ្ស-ហ្វ.កេណ្ណឌី» ដែលទុកជាកស្តុតាងនៃនាមវិថីថ្មីនេះ ។ តមកសម្តេចឪទ្រង់បានអញ្ជើញលោកជំទាវឡើងជិះរថយន្ត ដើម្បីធ្វើការទស្សនាតាមរុក្ខវិថី ហ្ស.ហ្វ កេណ្ណឌីនេះ ដែលមានបណ្តោយផ្លូវ ២.៩០០ ម៉ែត្រ ។

ក្រោយដែលចប់ពិធីសម្ពោធដាក់នាមរុក្ខវិថីថ្មីដ៏ល្អនេះរួចសព្វគ្រប់ហើយ សម្តេចឪទ្រង់បានអញ្ជើញលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី ព្រមទាំងមិត្តជិតស្និទ្ធរបស់លោកជំទាវ ចូលទៅសំណាក់នៅព្រះរាជដំណាក់ឈើតាល ក្នុងក្រុងព្រះសីហនុ ។

# ដំណើរទស្សនកិច្ចនៃលោកជំទាវ ហ្សាក់គីលីន-កេណ្ណឌីនៅប្រទេសកម្ពុជា



លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានចូលក្រាបបង្គំគាល់ និង សន្ទនាជាមួយសម្ដេចព្រះវររាជនីនាថ នៅក្នុងមហាប្រាសាទខេមរិន្ទ

## ការចូលក្រាបបង្គំគាល់ សម្ដេចព្រះមហាក្សត្រិយានី នៅព្រះបរមរាជវាំង



ទំព័រ/១៨ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានធ្វើដំណើរឡើងទៅប្រាសាទខេមរិន្ទ

នៅឱកាសសំរាកកាយនៅក្នុងព្រះរាជដំណាក់ឈើទាល នោះ លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទទួលពិសាភោជនាហារ ដ៏ប្រណីត ដែលសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានតាក់តែងជូនជាកិត្តិយស ។

នៅវេលារសៀលលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានអញ្ជើញទស្សនាតាមវិថីនានាក្នុងទីក្រុងព្រះសីហនុ ។ ក្នុងខណៈនោះលោកជំទាវមានការចាប់អារម្មណ៍ យ៉ាងខ្លាំងចំពោះការរៀបចំនិងទេសភាពដ៏ល្អនៃទីក្រុងថ្មីនេះ ។

ក្រោយដែលបានសំណាក់នៅទីក្រុងព្រះសីហនុ អស់ពេលមួយរាត្រីរួចហើយ នៅព្រឹកថ្ងៃទី ៧ វិច្ឆិកា ១៩៦៧ លោកជំទាវហ្សាក់គីលីន កេណ្ណឌី ក៏បានអញ្ជើញមកកាន់រាជធានីភ្នំពេញវិញ ។ លុះមកដល់ទីក្រុងភ្នំពេញហើយ លោកជំទាវ ក៏បានអញ្ជើញចូលទៅក្រាបថ្វាយបង្គំគាល់សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង នៅព្រះទីនាំងទេវាវិនិច្ឆ័យ ។

នៅវេលារសៀលលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានអញ្ជើញទស្សនាពិព័រណ៍អចិន្ត្រៃយ៍នៃសមិទ្ធិសង្គមរាស្ត្រនិយម និងអញ្ជើញទស្សនាទីក្រុងភ្នំពេញតាមរថយន្ត ដោយមានសម្ដេចឪទ្រង់បានស្ដេចយាងជូនដំណើរផង ។

នៅថ្ងៃទី ៨ វិច្ឆិកា ១៩៦៧

លោកជំទាវហ្សាក់គីលីន កេណ្ណឌី និង សម្ដេចឪ ទ្រង់ អមព្រះរាជដំណើរនៃសម្ដេចព្រះវររាជិនីនាថ ស្ដេចយាង ទៅកាន់ព្រះរាជដំណាក់





លោកជំទាវ ហ្សាក់គីលីន កេណ្ណឌី បានទស្សនារបាំព្រះរាជទ្រព្យ ▲



ម្ចាស់ក្សត្រី មុនិកុសុម បានសម្ដែងរបាំតុក្កតាជូនលោកជំទាវ ហ្សាក់គីលីន កេណ្ណឌី ទស្សនា

នេះ ក្រោយដែលលោក ជំទាវ ហ្សាក់គីលីន កេណ្ណឌី បាននៅសំណាក់ និង បានទស្សនាការនៅក្នុងប្រទេសកម្ពុជា យ៉ាងសុខសាន្ត និង យ៉ាងរីករាយនោះមក នៅម៉ោង ១០ ព្រឹក លោក ជំទាវ ក៏បានចាកចេញពីប្រទេសកម្ពុជា និវត្តទៅកាន់សហរដ្ឋអាមេរិកវិញ ។

នៅពេលលោកជំទាវនិវត្តទៅវិញនេះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ដោយមានឥស្សរជនខ្មែរ លោកជំទាវ - លោកស្រី - យុវជន-យុវតី និងប្រជាពលរដ្ឋជាច្រើនពាន់នាក់បានជូនដំណើរលោកជំទាវ យ៉ាងអឹកធឹក ដូចកាលដែលលោកជំទាវអញ្ជើញមកដល់ដែរ ។



ព្រះរាជនត្តានៃសម្ដេចព្រះវររាជិនីនាថ បានចូលទៅគួរសមនឹងលោកជំទាវហ្សាក់គីលីនកេណ្ណឌី